mult cultural health communication

NSW GOVERNMENT | Health

Khmer
[DOH-7095]

# ការឆ្លងវីរុស បារម៉ា ហ្វ័ររេស្ត (Barmah Forest)

## Barmah Forest virus infection

### តើវីរុស Barmah Forest ជាអ្វី?

- វីរុស Barmah Forest ជាមេរោគមួយប្រភេទដែលអាចឆ្លងទៅមនុស្សតាមរយៈមូសខាំ។
- ការឆ្លងវីរុស Barmah Forest នៅគ្រាអតីតកាល អាចផ្តល់នូវការបង្ការទប់ស្កាត់ការឆ្លងនៅពេលអនាគត។
- វីរុស Barmah Forest ជាប់ពូជសន្តានជាមួយនឹងវីរុស Ross River ។

### តើវីរុស Barmah Forest ឆ្លងរាលដាលយ៉ាងដូចម្តេច?

- វីរុសនេះឆ្លងតាមរយៈប្រភេទមូសញីមួយចំនួន។
- មូសញីបឺតឈាមពីសត្វនិងមនុស្ស ។ បើសិនវាបឺតឈាមពីសត្វដែលបានផ្ទុកមេរោគ មូសនោះអាចក្លាយទៅជាមូសផ្ទុកមេរោគ ។ បន្ទាប់មកវីរុសអាចឆ្លងបន្តទៅសត្វឬមនុស្សផ្សេងទៀតនៅពេលមូសដែលមានផ្ទុកមេរោគនោះខាំបឺតឈាមម្តងទៀត ។
- ពូជសត្វជាច្រើនដូចជាកង់ហ្គូរូ និង វ៉ាល់ឡាប៊ី (Wallabies) ត្រូវបានគេគិតថា ជាសត្វសំខាន់ៗដែលពាក់ព័ន្ធនៅក្នុងវដ្តនៃការឆ្លងជម្ងឺនេះ ។
- វីរុសនេះមិនឆ្លងពីមនុស្សម្នាក់ទៅម្នាក់ផ្សេងទៀតទេ ។

### តើជម្ងឺបង្កដោយវីរុស Barmah Forest មានរោគសញ្ញាអ្វីខ្លះ ?

- មនុស្សជាច្រើនដែលមានផ្ទុកវីរុសនេះនឹងមិនមានចេញជារោគសញ្ញាអ្វីទេ។
- រោគសញ្ញានៃជម្ងឺបង្កដោយវីរុស Barmah Forest ស្រដៀងគ្នានឹងជម្ងឺបង្កដោយវីរុស Ross River ដែរ។
- បណ្តារោគសញ្ញាដូចជម្ងឺផ្តាសាយអាចកើតមាន, ដោយមានឡើងកំដៅខ្លួន, រងារញាក់, ឈឺក្បាល, ឈឺសាច់ដុំនិងសន្លាក់
- មនុស្សខ្លះអាចមានហើមសន្លាក់និងរឹងសន្លាក់ជាពិសេសកត់សំគាល់ឃើញនៅពេលព្រឹក ។
- ជួនកាលមានឡើងកន្ទួល, ជាទូទៅនៅលើខ្លួនឬដៃជើង ។ ជាទូទៅស្នាមកន្ទួលនេះបាត់ទៅវិញ ក្រោយពី ៧-១០ ថ្ងៃ ។
- មានអារម្មណ៍ហេវហត់, អស់កំលាំងនៅក្នុងពេលកំពុងមានជម្ងឺ ដែលអាចប៉ះពាល់ដល់បែបបទនៃការរស់នៅ និងការអនុវត្តការងារ ។

## Further information – Public Health Units in NSW

**1300 066 055**

www.health.nsw.gov.au